# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពត**
សំណុំរឿងព្រហ្មទណ្ឌលេខ ២៥
ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២
សាលក្រមលេខ: **៨៣ (គ)**
ចុះថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ ២០២២

## <u>តាងនាមប្រជារាស្ត្រខ្មែរ</u>
## <u>សាលាដំបូងខេត្តកំពត</u>

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ១៩៩៣។

បានបើកកិច្ចពិភាក្សាដេញដោលជាសាធារណៈ នៅសាលាជំនុំជម្រះក្តីនៃសាលាដំបូងខេត្តកំពត នាថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ៩ និង ០០ នាទីព្រឹក។

**<u>ចៅក្រមជំនុំជម្រះ</u>**

**លោកស្រី [redacted] ជាចៅក្រមជំនុំជម្រះ**

**<u>តំណាងអយ្យការ</u>**

**លោក [redacted] ជាព្រះរាជអាជ្ញារង**

**<u>ក្រឡាបញ្ជីសវនាការ</u>**

**លោកស្រី [redacted] ជាក្រឡាបញ្ជី**

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ២៤ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ ២០២២ ដែលមានជនជាប់ចោទ:

-ឈ្មោះ [redacted] ណារ៉ូ ភេទប្រុស អាយុ ៣៤ ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅសព្វថ្ងៃភូមិ [redacted] ខេត្តកំពត ឪពុកឈ្មោះ [redacted] ប៊ុនវួច ( រ ) ,ម្តាយឈ្មោះ [redacted] មួយ ( រ ) នៅលីវ, ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន ។ ( សាលក្រមមុនអង្គសេចក្តីលេខ១៧ ( គ ) ចុះថ្ងៃទី០៥.០១.២០២២ )

-ដែលមានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

ជាប់ចោទពីបទៈលួច ( សម្ភារៈ) និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០២ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ០៨ និង ៣០នាទី បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣, មាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:**

កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០២ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ៨ និង ៣០ នាទី នៅចំណុចភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត មានករណី លួច ( សម្ភារ ) និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] ណារ៉ូ បានធ្វើសកម្មភាពចូលលួចក្នុងផ្ទះរបស់ជនរងគ្រោះឈ្មោះ [redacted]ពន្លឺ បណ្តាលឱ្យបាត់បង់សម្ភារៈដូចជា: ម៉ូទ័រកាត់ដែកពណ៌លឿង, ដែកជណ្តើរចំនួន០៣, ដែកជ្រុងចំនួន០២ ដើម,ដែកថ្ងៃចំនួន៤១ដើម, ដែករនាបរនាបចំនួន០៥ដើម ដែកសំណាញ់លួសចំនួន០២ដុំ,ដែកថ្នាំងអំពៅចំនួន២០ដើម, ដុយខ្យល់សម្រាប់ដាក់លាងម៉ូតូចំនួន ០២ឈុត, ឈើគ្រោងទ្វារចំនួន០១,ក្តារបន្ទះចំនួន ០៥សន្លឹក, កៅអីពូកម៉ូតូកង់បីចំនួន០២ និងទាកាប៉ាចំនួន ០២ក្បាល ។ នៅចំពោះមុខព្រះរាជអាជ្ញា ជនជាប់ចោទខាងលើ បានឆ្លើយសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តអំពើលួចខាងលើ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជម្រះភ្លាមលេខ ០៣ អ.យ.ខ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពត ។

-បានឃើញកំណត់ហេតុជំនុំជម្រះភ្លាមចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកំពត ។

-បានឃើញសាលក្រមមុនអង្គសេចក្តីលេខ ១៧ ( គ ) ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកំពត ។

-បានឃើញលេខចាត់តាំងចៅក្រមជំនុំជម្រះលេខ ៥៣ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២ របស់ឯកឧត្តមប្រធានសាលាដំបូងខេត្តកំពត ។

**<u>នាពេលសវនាការ</u>**

-ជនជាប់ចោទឈ្មោះ [redacted] ណារ៉ូ បានឆ្លើយថា:ខ្ញុំពិតជាបានប៉ុនប៉ងលួចដែកគេមែន គឺដែកអេតចាយ លួច៣ ដង លួចនៅផ្ទះគេទុកចោល ខ្ញុំគ្មានគម្រោងលួចទេ គឺខ្ញុំដើរប៉ះក៏លួចតែម្តង លួចបានយកទៅលក់ឲ្យអ្នកលក់អេតចាយ ឃ្លាតពីផ្ទះលក់ប្រហែល១០០ ម៉ែត្រ ហើយម្ចាស់គេប្តឹង ក៏ចាប់បានតែម្តងទៅ ។ ការលួចទាំងបីលើក ទី១ បានម៉ូទ័រ១ លក់បាន៣៥.០០០ ( បីម៉ឺនប្រាំពាន់ ) រៀល,ទី២ លក់បាន ២៥.០០០រ ( ពីរម៉ឺនប្រាំពាន់ ) រៀល , ទី៣ លក់បានបាន ២៥.០០០រ ( ពីរម៉ឺនប្រាំពាន់ ) រៀល ដូចគ្នា ។ កន្លងមកខ្ញុំធ្លាប់ប្រើប្រាស់គ្រឿងញៀន ប្រហែល១ អាទិត្យ មុនពេលគេចាប់ខ្លួន ប្រើជាមួយជាងដែកដូចគ្នា ជក់បានតែ២ ហឺត ទេ តែអត់ញៀនទេ ។ ម្ចាស់គេចាប់បាននៅកន្លែងលក់អេតចាយ ហើយម្ចាស់គេបានប្រាប់ឲ្យខ្ញុំសារភាពអស់ទៅ ខ្ញុំក៏បានឆ្លើយសារភាពអស់ហើយ ។ គេចាប់ខ្ញុំបាននៅផ្ទះខ្ញុំ ពេលខ្ញុំទៅលក់បានហើយ មកដល់ផ្ទះគេចាប់ខ្លួនតែម្តង ។ លួចលើកទី១ , ទី២ និងទី៣ លក់បានជាង១០.០០០រ ( ជាងមួយម៉ឺន ) រៀល ហើយយកទៅទិញនំហូប ។ ខ្ញុំទទួលស្គាល់ថាពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ពេលនេះខ្ញុំមានការស្តាយក្រោយយ៉ាងខ្លាំង ថ្ងៃក្រោយខ្ញុំកែខ្លួន ឈប់ប្រព្រឹត្តអំពើបែបនេះទៀតហើយ ខ្ញុំនឹងកែខ្លួនឲ្យល្អឡើងវិញ ឲ្យក្លាយ

Scanned with CamScanner

ជាពលរដ្ឋដ៏ល្អនឹងគេ ។ ខ្ញុំពិតជាបានលួច ៣ដង ដូចការចោទប្រកាន់មែន ហើយលក់បានសរុប ៣៩.០០០ ( បីម៉ឺនប្រាំបួនពាន់ ) មែន ខ្ញុំមានសាក្សី ។ ខ្ញុំលួចអីវ៉ាន់គេបាន៣ ដងមែន មានៈ ម៉ូទ័រកាត់ដែក, ដែកជ្រុង និងដែកកណ្ដាល អីវ៉ាន់អស់នោះម្ចាស់គេបានយកវិញអស់ហើយ ។ ពេលខ្ញុំលួចឥវ៉ាន់គេបានហើយ យកទៅលក់ឲ្យគេៗតែងតែថតរូបខ្ញុំទុករហូត ខ្ញុំអត់បានសួរនាំគេទេ ។

-តាមអំនានកំណត់ហេតុបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] នៅដំណាក់កាលសមត្ថកិច្ចចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២២ បានឆ្លើយថាៈ នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០២២ ម៉ោងប្រហែល៧ ព្រឹក មានជនសង្ស័យមិនស្គាល់សាវតា បានធ្វើសកម្មភាពផ្លោះរបងចូលក្នុងផ្ទះរបស់ខ្ញុំ នៅភូមិក្រាំង លួចទ្រព្យសម្បត្តិ បណ្ដាលឱ្យបាត់បង់ៈ ដែកជ្រុងកែច្នៃ ជង្គង់សេះ ( ជណ្ដើរ ) ចំនួន១ ដែកជ្រុងទំហំ៤០x៨០ស.ម ប្រវែងប្រមាណ ៣ ម ។ កន្លងមកនៅក្នុងខែ១២ ឆ្នាំ២០២១ នេះ គឺចាប់ពីថ្ងៃទី១៧.១២.២០២១ មិនដឹងវេលាម៉ោង គឺមានជនសង្ស័យ មិនស្គាល់សាវតាផ្លោះរបង ចូលលួចទ្រព្យសម្បត្តិរបស់ខ្ញុំរួមមានៈ ម៉ូទ័រកាត់ដែកចំនួន១ ម៉ូទ័រខាត់ធំ ចំនួន០១ ដែករនាបទំហំ២០x៤០ ស.ម ប្រវែង៦ម ចំនួន០៥ ដើម ។ នៅថ្ងៃទី២០.១២.២០២១ មិនដឹងវេលាម៉ោង បាត់បង់រួមមានៈ ដែកជ្រុង៤០x៨០ ស.ម ប្រវែង៦ម មិនដឹងចំនួន, ដែកជ្រុង៣០x៣០ ស.ម ប្រវែង៦ ម ចំនួន០១ ដើម, ដែកជ្រុង២០x២០ ស.ម ប្រវែង ៦ម ចំនួន០២ដើម , ដែក៤០x៤០ ប្រវែង៦ ម ចំនួន០២ ដើម ។ នៅថ្ងៃទី២២.១២.២០២១ មិនដឹងវេលាម៉ោង បាត់បង់រួមមានៈ ដែកកាត់ជាកំណាត់ចំរុះមួយរទេះអូស ។ នៅថ្ងៃទី២៥.១២.២០២១ មិនដឹងវេលាម៉ោង បាត់បង់រួមមានៈ ដែកសំណាញ់លួសកម្ពស់១,០២ស.ម ចំនួន០២ ដុំធំ, ដែកថ្នាំងអំពៅកាត់ធ្វើជើងកញ្ច្រែងចំនួន២០ ដើម ។ នៅថ្ងៃទី ២៩.១២.២០២១ មិនដឹងវេលាម៉ោងបាត់បង់រួមមានៈ ដែកជ្រុងជណ្ដើរចំនួន០១, ដុយខ្យល់សម្រាប់ដាក់ម៉ូតូលាងចំនួន០២ ឈុត, គ្រោងទ្វារឈើសម្រាប់ដាក់ឥដ្ឋ២០ ចំនួន០១ , ក្ដារបន្ទះប្រវែង ៣ម ចំនួន ០៥សន្លឹក, កៅអីពូកម៉ូតូកង់បីចំនួន០២កៅអី, សត្វទាកាប៉ាចំនួន ០៣ក្បាល ។ ដោយឡែកខ្ញុំបានទៅសាកសួរប្រជាពលរដ្ឋរស់នៅក្បែរផ្ទះខ្ញុំ ក្នុងភូមិក្រាំង សង្កាត់ក្រាំងអំពិល នោះថាឈ្មោះ សល់ ភេទប្រុស ជាប្រជាពលរដ្ឋរស់នៅភូមិក្រាំង ឃុំត្រពាំងធំ ស្រុកទឹកឈូ ខេត្តកំពត គឺជាមនុស្សមិនល្អ ខិលខូច ដើរលួចទ្រព្យសម្បត្តិគេ ឱ្យតែអ្នកណាហ៊ាននិយាយពីវា គឺវាលួចផ្ទះអ្នកនោះតែម្ដង ។ សំណូមពរៈ សូមឱ្យសមត្ថកិច្ចជួយស្រាវជ្រាវ រកជនល្មើសមកចោទប្រកាន់តាមច្បាប់ និងទាមទារទ្រព្យសម្បត្តិរបស់ខ្ញុំមកវិញ ។

-តាមអំនានចម្លើយរបស់សាក្សីឈ្មោះ [redacted] លោត នៅដំណាក់កាលសមត្ថកិច្ចចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២២ បានឆ្លើយបំភ្លឺថាៈនៅក្នុងខែធ្នូ ឆ្នាំ២០២១ ខ្ញុំមិនចាំថ្ងៃ(១៧.១២.២០២១) ម៉ោងប្រមាណ ០៩ព្រឹក ឈ្មោះ សល់ ( [redacted] ) ភេទប្រុស អាយុប្រហែល៣០ ឆ្នាំ ជាង ជាប្រជាពលរដ្ឋរស់នៅក្នុងភូមិក្រាំង ឃុំត្រពាំងធំ ស្រុកទឹកឈូ ខេត្តកំពត បានយកម៉ូទ័រកាត់ពណ៌លឿងចំនួន០១ មកលក់ឱ្យខ្ញុំ អ្នកទិញអេតចាយ ខ្ញុំឱ្យតម្លៃ៣៥,០០០ ( បីម៉ឺនប្រាំពាន់ ) រៀល ហើយខ្ញុំបានសួរវាថា យកម៉ូទ័រមកពីណា បានយកមកលក់ឱ្យខ្ញុំ វាប្រាប់ថា យកមកពីផ្ទះវាមក ។ ក្រោយមកទៀតមិនចាំថ្ងៃក្នុងខែ ១២ ដែរ នោះ ឈ្មោះ សល់ បានយកដែកជ្រុង ៤០x៨០ ស.ម ប្រវែង ៣ម ជាង មកលក់ឱ្យខ្ញុំ ហើយឱ្យតម្លៃ ១៣,០០០ ( មួយម៉ឺនបីពាន់ ) រៀល ដោយឡែកមកដល់ថ្ងៃទី០២.០១.២០២២ ម៉ោង ៨ព្រឹក ឈ្មោះ សល់ ដដែលនោះ បានយកដែកច្នៃជង្គង់សេះ ( ជណ្ដើរ ) ចំនួន០២ យកមកលក់ឱ្យខ្ញុំ ទៀត ខ្ញុំឱ្យតម្លៃ

១៩,០០០ ( មួយម៉ឺនប្រាំបួនពាន់ ) រៀល នៅថ្ងៃនោះដែរ ក៏មានសមត្ថកិច្ចមកសួរនាំរឿងទិញអេតចាយ ខ្ញុំបានប្រាប់សមត្ថកិច្ចថា មានឈ្មោះ សល់ ( [redacted] ណារ៉ូ ) បានយកសម្ភារទាំងនោះមកលក់ឱ្យខ្ញុំ ហើយសម្ភារទាំងអស់នោះ ខ្ញុំបាទសុខចិត្តប្រគល់ជូនសមត្ថកិច្ចទុកជាភស្តុតាង ។ មិនត្រឹមតែប៉ុណ្ណោះ នាងខ្ញុំបានថតរូបឈ្មោះ [redacted] ណារ៉ូ ហៅសល់ , ញ៉ាល់ ទុកក្នុងពេលទិញសម្ភារ ហើយខ្ញុំក៏បានបង្ហោះរូបភាព [redacted] ណារ៉ូ នោះជូនសមត្ថកិច្ចនគរបាល ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការរួចមក ឃើញថាពេលនេះជនជាប់ចោទ បានឆ្លើយសារភាពគ្រប់ចំណុចអស់ហើយ ខ្ញុំតំណាងអយ្យការសូមធ្វើសេចក្តីតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះភ្លាមលេខ ០៣ អ.យ.ខ ចុះថ្ងៃទី ០៤-០១-២០២២ ទុកជាបានការដដែល និងប្តឹងសុំឲ្យលោកស្រីចៅក្រមសម្រេចវិនិច្ឆ័យទោសជនជាប់ចោទតាមច្បាប់ ។

មេធាវីបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់អង្គសវនាការរួចមក ឃើញថាពេលនេះ កូនក្តីខ្ញុំបានឆ្លើយសារភាពគ្រប់ចំណុចអស់ហើយថា គាត់ពិតជាបានលួច និងប្រើប្រាស់សារធាតុញៀនដោយខុសច្បាប់ ពិតមែនតែបដិសេធថាអត់បានកាត់របងទេ គឺរបងគេបាក់ស្រាប់ ។ ខ្ញុំសំណូមពរ សូមលោកស្រីចៅក្រម មេត្តាបន្ធូរបន្ថយទោស ដើម្បីផ្តល់ឱកាសឲ្យកូនក្តីខ្ញុំបានកែប្រែខ្លួនឲ្យក្លាយជាពលរដ្ឋល្អនឹងគេទៅថ្ងៃមុខ ។

-ជនជាប់ចោទឈ្មោះ [redacted] ណារ៉ូ បានឆ្លើយថា ៖ ខ្ញុំសំណូមពរនូវសំដីចុងក្រោយថា សូមឲ្យតុលាការបន្ធូរបន្ថយទោសឲ្យខ្ញុំបាទផង ។

-ក្រោយពីបានដំណើរការកិច្ចសួរដេញដោល

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំនានចម្លើយរបស់ដើមបណ្តឹង និងសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងខេត្តកំពត**

**<u>យល់ឃើញថា</u>**

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ណារ៉ូ ហៅ សល់ បានសារភាពទទួលស្គាល់ថាខ្លួនពិតជាបានប្រព្រឹត្តបទល្មើស លួច ( សម្ភារ ) និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន មែនគប្បីតុលាការពិចារណា និងសម្រេច ។

-ផ្អែកតាមកំណត់ហេតុបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពន្លី និងតាមចំអំនានចម្លើយរបស់សាក្សីឈ្មោះ [redacted] លោត បានបញ្ជាក់បង្ហាញឱ្យឃើញថាជនជាប់ចោទឈ្មោះ [redacted] ណារ៉ូ ហៅ សល់ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការប្រាកដមែន ។

-អំពើរបស់ជនជាប់ចោទ បានបង្ហាញឱ្យឃើញពីចេតនាទុច្ចរិតក្នុងការដកហូតទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដែលអំពើនេះបានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម និងទ្រព្យសម្បត្តិរបស់អ្នកដទៃ ។

Scanned with CamScanner

-ជនជាប់ចោទ ជានីតិជនហើយមាននីតិសម្បទាគ្រប់គ្រាន់ដោយពុំមានសញ្ញាណណាមួយ ដែលបង្ហាញ ឱ្យឃើញមានមន្ទិលសង្ស័យថា ជនជាប់ចោទមានបញ្ហាវិបល្លាសស្មារតីក្នុងពេល ឬ ក្រោយពេលប្រព្រឹត្តបទល្មើសឡើយ ។ ជនជាប់ចោទជាសមត្ថជន ដែលមានវិចារណញ្ញាណគ្រប់គ្រាន់ក្នុងការយល់ដឹងពីអំពើល្មើសរបស់ខ្លួន ។

-ផ្អែកតាមកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀន ចុះថ្ងៃទី ០២ ខែមករា ឆ្នាំ ២០២២ របស់អធិការដ្ឋាននគរបាលក្រុងកំពត បានធ្វើតេស្តទឹកនោមឈ្មោះ [redacted] ណារ៉ូ ហៅ សល់ ឃើញថាពិតជាមានសារធាតុញៀនខុសច្បាប់ប្រាកដមែន ។

មានពិរុទ្ធភាពគ្រប់គ្រាន់លើៈ ជនជាប់ចោទឈ្មោះ [redacted] ណារ៉ូ ភេទ ប្រុស អាយុ ៣៤ ឆ្នាំ ជនជាតិខ្មែរ ។

ពីបទៈ លួច ( សម្ភារៈ) និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០២ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ០៨ និង ៣០នាទី បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣, មាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-ដើមបណ្តឹងរដ្ឋប្បវេណីមិនបានទាមទារសំណង ដូច្នេះតុលាការមិនគប្បីពិចារណាអំពីសំណងទេ ។

**ហេតុដូច្នេះសាលាដំបូងខេត្តកំពត**

**វិនិច្ឆ័យសេចក្តី**

ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ណារ៉ូ ភេទ ប្រុស អាយុ ៣៤ ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល០៦ ( ប្រាំមួយ ) ខែ ដោយគិតចាប់ពីថ្ងៃឃុំខ្លួន ។

ពីបទៈ លួច ( សម្ភារៈ) និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០២ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ០៨ និង ៣០នាទី បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣, មាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

សាលក្រមប្រកាសជាសាធារណៈនៅថ្ងៃទី ០៧ ខែមករា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ណារ៉ូ ហៅ សល់ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និង កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពន្លី ។

ទុកសិទ្ធិអោយប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា

[redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា

[redacted]

---

“បានចម្លងត្រឹមត្រូវតាមច្បាប់ដើម”

ថ្ងៃ ចន្ទ ៦កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

កំពត, ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២

**ចៅក្រមជំនុំជម្រះ**

[redacted]

Scanned with CamScanner